ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមីនា និងទិសដៅការងារខែមេសា ឆ្នាំ២០១៤

នៅក្នុងខែមីនានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្ម លើការដ្ឋានជាច្រើន ដោយផ្សារភ្ជាប់បទដ្ឋាន ការងាររដ្ឋបាល បច្ចេកទេស នីតិវិធី និងហិរញ្ញវត្ថុ ជាពិសេសការងារពាក់ព័ន្ធនឹងមូលដ្ឋានរបស់ថ្នាក់ដឹកនាំ សមាជិក-សមាជិកាព្រឹទ្ធសភា ដើម្បីលើកកម្ពស់មុខងារតំណាង មុខងារត្រួតពិនិត្យ និងមុខងារនីតិកម្ម ការបណ្តុះបណ្តាលធនធានមនុស្ស ការងារកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងបញ្ហាផ្សេងៗទៀត និងខិតខំពង្រឹងពង្រីកភាពសុខដុមផ្ទៃក្នុង បង្កើតសេវាថ្មីៗ ការកសាងគោលនយោបាយនានា បង្កើនកិច្ចសហប្រតិបត្តិការជាតិ អន្តរជាតិ និងបំពេញការងារសំខាន់ៗមួយចំនួនទៀតដូចខាងក្រោម៖

## I.លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖

-បានចាត់ចែងរៀបចំកិច្ចប្រជុំពិនិត្យ និងតាក់តែងឯកសារ ស្តីពីសេចក្តីកំណត់ និងនីតិវិធីអនុវត្តចំពោះប្រការទាំងឡាយនៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នីតិកាលទី៣ និងសិក្ខាសាលាស្តីពីការចូលរួមរបស់ស្ត្រីដើម្បីលើកកម្ពស់តម្លៃសីលធម៌សង្គម បទឧទ្ទេសនាមអំពីតួនាទី ភារកិច្ច សមត្ថកិច្ចរបស់ព្រឹទ្ធសភា និងពិធីបំពាក់គ្រឿងឥស្សរិយយស និងមេដាយ ការងារជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមក្នុងពិធីផ្សព្វផ្សាយ ស្តីពីច្បាប់អចលនវត្ថុនៅកម្ពុជា និងជួបប្រជុំពិភាក្សាការងារជាមួយ ឯកឧត្តម លោកជំទាវជាប្រធានគណៈកម្មការ ចូលរួមមហាសន្និបាតលើកទី១៣០ របស់សហភាពអន្តរសភា(IPU) និងចូលរួមកិច្ចប្រជុំសមាគមអគ្គលេខាធិការសភា (ASGP) នៅទីក្រុងហ្សឺណែវ នៅប្រទេសស្វីស ចូលរួមប្រជុំពិភាក្សាការងារផ្សេងៗ ព្រមទាំងបានពិនិត្យសម្រេចលើឯកសារផ្សេងៗ ចំនួន៥៤៥ច្បាប់ ។

## ១.សេវាទទួលខុសត្រូវមុខងារត្រួតពិនិត្យ៖

-បានចុះបំពេញការងារអមជាមួយសមាជិក-សមាជិកា គណៈកម្មការនានា របស់ព្រឹទ្ធសភា ក្នុងជំនួបសវនាការជាមួយថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ដើម្បីស្វែងយល់អំពីការអប់រំ



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

ទាក់ទងនឹងសិទ្ធិមនុស្ស នៅគ្រប់ភូមិសិក្សា ។

**២.សេវាទទួលបន្ទុកខាងតំណាង៖**

-បានរៀបចំវេទិកាថ្នាក់ស្រុកចំនួន០២លើក ស្តីពី "ព្រឹទ្ធសភា និងការពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំក្នុងការអភិវឌ្ឍមូលដ្ឋាន និងសមភាពយេនឌ័រ" និង "សេវាសាធារណៈរបស់ឃុំ" នៅស្រុកអង្គស្នួល ខេត្តកណ្តាល និងស្រុកស៊ិធរកណ្តាល និងស្រុកពារាំង ខេត្តព្រៃវែង ។

-រៀបចំបែបបទ និងអមដំណើរថ្នាក់ដឹកនាំ សមាជិក-សមាជិកាព្រឹទ្ធសភា ចុះទៅតាមបណ្តាខេត្ត រាជធានី ទូទាំងប្រទេសចំនួន៩០លើក ដើម្បីសំណេះសំណាល សាកសួរសុខទុក្ខ សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ប្រជាពលរដ្ឋ ព្យាបាលជំងឺ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា ស្វែងយល់ និងតាមដានការអនុវត្តច្បាប់ គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ស្វែងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន ផ្សព្វផ្សាយព័ត៌មាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗ សរុបចំនួន១៦៥លើក ។

-ទទួលពាក្យបណ្តឹង ចំនួន០៣ករណី ។

**៣.សេវាទទួលបន្ទុកខាងព័ត៌មាន៖**

-បានអមដំណើរសមាជិក-សមាជិកា គណៈកម្មការនានា របស់ព្រឹទ្ធសភា បានចុះបំពេញបេសកកម្មទៅខេត្តកោះកុង ខេត្តព្រះសីហនុ ខេត្តកំពត ខេត្តកែប ខេត្តតាកែវ ខេត្តកំពង់ធំ ខេត្តសៀមរាប និងខេត្តត្បូងឃ្មុំ ដើម្បីសិក្សាស្វែងយល់អំពីការអនុវត្តច្បាប់អន្តោប្រវេសន៍ ការផ្សព្វផ្សាយព័ត៌មាន បញ្ហាប្រឈមនានា ដែលពាក់ព័ន្ធជាមួយវិស័យអប់រំ ធម្មការ សាសនា វប្បធម៌ ទេសចរណ៍ សម្រង់ព័ត៌មានពាក់ព័ន្ធទៅនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ និងស្រាវជ្រាវប្រមូលព័ត៌មាន ដើម្បីត្រៀមរៀបចំវេទិកាភូមិភាគ និងចុះទៅខេត្តតាកែវ កំពត កែប កំពង់ចាម និងខេត្តរតនគិរី ដើម្បីសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ និងប្រជាពលរដ្ឋ និងស្រាវជ្រាវព័ត៌មានពាក់ព័ន្ធទៅនឹងវិស័យជាសមត្ថកិច្ចនៅភូមិភាគទី២ និងភូមិភាគទី៥ និងមន្ត្រីចំនួន១២នាក់ បានចុះបេសកកម្មទៅ ខេត្តកណ្តាល ឧត្តរមានជ័យ ស្ទឹងត្រែង និងរតនគិរី ដើម្បីស្រាវជ្រាវប្រមូលព័ត៌មាន សម្រាប់ត្រៀមរៀបចំវេទិកា ជូនក្រុមសមាជិកព្រឹទ្ធសភា ប្រចាំភូមិភាគទី៣ ភូមិភាគទី៤ និងភូមិភាគទី៨ ។

**៤.ការងារអន្តរជាតិ៖**

រៀបចំបែបបទជូនគណៈកម្មការព្រឹទ្ធសភាទៅ៖

-បំពេញទស្សនកិច្ច នៅប្រទេសវៀតណាម និងអ៊ីរ៉ង់

-ចូលរួមមហាសន្និបាត លើកទី១៣០ របស់សហភាពអន្តរជាតិ (IPU) នៅប្រទេសស្វីស

-មន្ត្រីចំនួន០២រូប បានចូលរួមហ្វឹកហ្វឺនការងារស្រាវជ្រាវរយៈពេល០១ឆ្នាំ នៅវិទ្យាស្ថានសភា

កម្ពុជា ។

-ទំនាក់ទំនងជាមួយដៃគូអន្តរជាតិនានា (ឥណ្ឌា ប្រ៊ុយណេ ហ្វីលីពីន ឥណ្ឌូនេស៊ី ម៉ាឡេស៊ី វៀតណាម ថៃ រុស្ស៊ី អាល្លឺម៉ង់ អូស្ត្រាលី ស្កាតកុងស៊ុលបែលហ្ស៊ិក ស្កាតកុងស៊ុលន័រវ៉េស ) ដើម្បីសុំអាហារូបករណ៍ និងទស្សនកិច្ចសិក្សា ។

**៥.ទំនាក់ទំនងសាធារណៈ**

-ទំនាក់ទំនងជាមួយស្ថានីយ៍ទូរទស្សន៍ជាតិ ទូរទស្សន៍អាស៊ីអាគ្នេយ៍ ដើម្បីផ្សព្វផ្សាយសមិទ្ធផលនានារបស់ព្រឹទ្ធសភា និងសាកលវិទ្យាល័យ CUS, CMTC, CDC, AEU, ECCC, CWF, NIDA, Hong kong Center ដើម្បីសុំអាហារូបករណ៍ និងទស្សនកិច្ចសិក្សា ។

-បានទទួលមន្ត្រីរាជការ សិស្ស និស្សិត សាធារណៈជន ចូលអានសៀវភៅ ចំនួន៣០០នាក់ និងទទួលនិស្សិតសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចចំនួន១០០នាក់ មកទស្សនកិច្ចព្រឹទ្ធសភា ។

**៦.ការអភិវឌ្ឍន៍ធនធានមនុស្ស៖**

-បើកវគ្គបណ្តុះបណ្តាលក្នុងប្រទេស ចំនួន០៨វគ្គ ស្តីពីមូលដ្ឋានគ្រឹះ និងការតបណ្តាញ វគ្គភាសាជប៉ុន ជំហានទី៥ វគ្គភាសាចិន (ជំហានទី៥ និងជំហានទី៦ ) វគ្គAdobe Premiere Video Edit វគ្គការហ្វឹកហ្វឺនការងារស្រាវជ្រាវ វគ្គភាសាបារាំងថ្នាក់ដំបូង វគ្គភាសាបារាំងថ្នាក់សំរាប់អ្នកចេះច្រើន ។

-មន្ត្រីចំនួន០៧នាក់ ទទួលអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រ នៅតាមសាកលវិទ្យាល័យក្នុងប្រទេស ។

-មន្ត្រីចំនួន០២រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី Public Governance and administration និងវគ្គការគ្រប់គ្រងលទ្ធភាពផលិតកម្មសម្រាប់មន្ត្រីរាជការ នៅប្រទេសសឹង្ហបុរី និង០១រូបទៀត ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី Advance Certificate in Web Design &Develop at the Aptech LTD នៅប្រទេសឥណ្ឌា ។

-មន្ត្រីចំនួន០២នាក់ ទទួលអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ នៅប្រទេសវៀតណាម ។

**៧.ការអភិវឌ្ឍស្ថាប័ន៖**

-ភាគីចិនកំពុងសិក្សាគំរោងសាងសង់អគារ១ខ្នង៣ជាន់ទៀត សម្រាប់ធ្វើជាការិយាល័យថ្នាក់ដឹកនាំព្រឹទ្ធសភាបំពេញការងារ ។

-រដ្ឋសភាវៀតណាមឯកភាពផ្តល់ជំនួយបំពាក់ប្រព័ន្ធIT នៅក្នុងព្រឹទ្ធសភាកម្ពុជា ។

**៨. ការងារផ្ទៃក្នុង សន្តិសុខ ធនធាន មធ្យោបាយ ទីកន្លែង៖**

-រៀបចំ និងកែសម្រួលផែនការលទ្ធកម្ម ឆ្នាំ២០១៨ ឆ្ពងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អនុវត្តការងារលទ្ធកម្មសារធារណៈ)

-ផ្សព្វផ្សាយខ្សែវីដេអូសម្រាប់ខួបអនុស្សាវរីយ ព្រឹទ្ធសភា នីតិកាលទី៣

-អនុវត្តតាមសេចក្តីណែនាំថ្មីរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការបញ្ចប់សេវារបស់ធនាគារANZ ក្នុងការបើកផ្តល់បៀវត្សជូនមន្ត្រីរាជការ

-មន្ត្រីរាជការបានចុះបេសកកម្មអមដំណើរគណៈប្រតិភូព្រឹទ្ធសភា ចំនួន០៤លើក

-រៀបចំទីកន្លែង និងបដិសណ្ឋារកិច្ចក្នុងកិច្ចជំនួបចរចារវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ

-វាយតម្លៃការអនុវត្តផែនការប្រតិបត្តិសម្រាប់ត្រីមាសទី១ ឆ្នាំ២០១៤

-អនុវត្តការជំរឿនសារពើភ័ណ្ឌឡើងវិញ និងរាយការណ៍ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-អង្គភាពសន្តិសុខផ្ទៃក្នុងព្រឹទ្ធសភា បានចាត់កងកម្លាំងការពារសន្តិសុខ សណ្តាប់ធ្នាប់ ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗ ចំនួន០៥លើក ។

-ថតចម្លងឯកសារ ចំនួន១១៣សំណើ ចងក្រងឯកសារជាសៀវភៅ ចំនួន៣៨ក្បាល ដោះស្រាយសំណើថវិកា ចំនួន២៦២សំណើ និងសម្ភារចំនួន៧៤សំណើ ព្រមទាំងផ្តល់សេវាដឹកជញ្ជូនចំនួន១១២លើក ។

-ប្រគល់កុំព្យូទ័រលើតុ ព្រីនធ័រ កៅអី ចំនួន៣៤គ្រឿង និងបំពាក់ទូរទស្សន៍ និងជើងស្វាយចំនួន១១គ្រឿង ។ បញ្ចូលហ្គាស ជួសជុល ម៉ាស៊ីនត្រជាក់ បន្ទប់ទឹក ទូរស័ព្ទ ប្តូរអំពូល ព្រី កុងតាក់ ក្រណាត់កៅអី ចំនួន៦៤គ្រឿង ។

-ជួសជុលកុំព្យូទ័រ ត្រួតពិនិត្យ បញ្ចូលកម្មវិធីកំចាត់មេរោគ Update Files Antivirus បញ្ចូលកម្មវិធីខ្មែរ Unicode, Office ចុះតាមដាន Internet និង Network សរុបចំនួន៥៣គ្រឿង និងបាន Upload ព័ត៌មាន និងឯកសារផ្សេងៗ ចំនួន៥០ ប្រធានបទ ។

## II.**ទិសដៅការងារខែមេសា ឆ្នាំ២០១៤**

១-ត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំវិសាមញ្ញ ព្រឹទ្ធសភា ។

២-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំជាមួយគណៈប្រតិភូបរទេស និងអគ្គទូតនានា ។

-ត្រៀមលក្ខណៈការប្រារព្ធពិធីបុណ្យចូលឆ្នាំថ្មី ។

-ត្រៀមរៀបចំជាបន្តបន្ទាប់ជំនួបរវាងតំណាងគណបក្សប្រជាជនកម្ពុជា និងតំណាងគណបក្សសង្គ្រោះជាតិ ។

៣-ត្រៀមសម្រួលការជួបសវនាការរវាងគណៈកម្មការជំនាញ និងក្រសួងស្ថាប័ននានា និងការចុះបេសកកម្មតាមបណ្តាខេត្ត ។

៤-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស ។

៥-ការរៀបចំវេទិកាសាធារណៈរបស់ក្រុមសមាជិកព្រឹទ្ធសភា តាមភូមិភាគ រួមទាំងវេទិកាក្រុមសមាជិកាព្រឹទ្ធសភា ។

៦-ការត្រៀមរៀបចំជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ចុះសួរសុខទុក្ខកងទ័ពនៅកោះពូឡូវ៉ៃ និងតាមដានដំណើរការកសាងអគារជូនកំលាំងនគរបាលឈរជើង នៅព្រំដែនឡាវ-កម្ពុជា (ខេត្តស្ទឹងត្រែង) ។

៧-ជម្រុញលើកកម្ពស់ចំណេះដឹង ការបើកវគ្គសិក្សាជំនាញ ភាសាបរទេស និងបច្ចេកវិទ្យាព័ត៌មាន និងយកចិត្តទុកដាក់ដល់ការពង្រឹងវិន័យ និងសណ្តាប់ធ្នាប់សាធារណៈ ។

៨-បន្តតាមដានគម្រោងសាងសង់អគារថ្មីជាមួយទីប្រឹក្សាពាណិជ្ជកម្មចិន ។

-ចាត់ចែងជួសជុល និងទំនើបកម្មសាលសិក្ខាសាលាខាងជើង-ខាងត្បូង ។ សហការជាមួយសម្ព័ន្ធភាពឃុំ-សង្កាត់ និងវិទ្យាស្ថានសភាកម្ពុជា អំពីការផ្ទេរអគារ និងជួសជុលអគារ ។

-បន្តការងារជំរឿនសារពើភ័ណ្ឌជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៩-បន្តអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន តាមកិច្ចសហប្រតិបត្តិការជាមួយវៀតណាម ចិន កូរ៉េ ឥណ្ឌា និងជប៉ុន ។

១០-បន្តយុទ្ធនាការស្វែងរកការគាំទ្រ និងជំនួយពីប្រភពក្នុង/ក្រៅប្រទេសសំរាប់ព្រឹទ្ធសភា តាមរយៈវិទ្យាស្ថានសភាកម្ពុជា ។

-កិច្ចសហប្រតិបត្តិការជាមួយ KOICA, JICA, CAMSERV, VN, ឥណ្ឌូនេស៊ី សឹង្ហបុរី ម៉ាឡេស៊ី កូរ៉េ ចិន ប្រ៊ុយណេ វិទ្យាស្ថានធនាគារពិភពលោក វិទ្យាស្ថានសភាកម្ពុជា ។

-បន្តសហប្រតិបត្តិការល្អជាមួយទីប្រឹក្សាអាល្លឺម៉ង់ថ្មី ។

១១-រៀបចំចងក្រងប្រវត្តិព្រឹទ្ធសភា និងប្រវត្តិអគារក្រហម អគារ៤ខ្នង ជាជំនួយរបស់ចិន និងអគារ២ខ្នង ជាជំនួយរបស់ជប៉ុន ។ ធ្វើបច្ចុប្បន្នភាព និងថែរក្សាឯកសារ សហប្រតិបត្តិការជាមួយដៃគូ ។

១២បង្កើនសមត្ថភាពស្រាវជ្រាវអំពីឯកសារបច្ចុប្បន្នភាពរបស់ជាតិ ។

១៣-បញ្ចប់នីតិវិធីលទ្ធកម្ម និងត្រៀមកាត់ឯកសណ្ឋានជូនមន្ត្រីរាជការ សម្រាប់ឆ្នាំ២០១៤ ។

១៤-ត្រៀមបើកប្រាក់ឧបត្ថម្ភ ពិធីសូត្រមន្តរាប់បាត រៀបចំពិធីជប់លៀង ល្បែងកំសាន្តតាមប្រពៃណី របាំត្រុត និងពិធីផ្សេងៗទៀត ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ។

-ការបែងចែកប័ណ្ណជូនពរ និងផ្សព្វផ្សាយសារជូនពរឲ្យបានទាន់ពេលវេលា ។

១៥-រៀបចំបែបបទសំរាប់ការអនុវត្តបើកបៀវត្សមន្ត្រីរាជការពីធនាគារ ACLEDAវិញ (តាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) ។

១៦-សិក្សាអំពីការដាក់ឲ្យអនុវត្តអង្គភាពថវិកា សម្រាប់៤អង្គភាពជាជំហានដំបូង ។

-ការត្រៀមរៀបចំកសាងគម្រោងថវិកាព្រឹទ្ធសភា ឆ្នាំ២០១៥ តាមវិធានថ្មី របស់ក្រសួងសេដ្ឋកិច្ច

និងហិរញ្ញវត្ថុ ។

១៧-បន្តពង្រឹងដំណើរការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងជំរុញការចាប់ផ្តើមដំណើរការរបស់អង្គភាពសវនកម្មផ្ទៃក្នុង ។

**III.សេចក្តីសន្និដ្ឋាន**

ក្នុងខែមីនានេះ ជារយៈពេលវិស្សមកាលរបស់ព្រឹទ្ធសភា ដែលថ្នាក់ដឹកនាំ សមាជិក-សមាជិកា ព្រឹទ្ធសភា បានយកចិត្តទុកដាក់ខ្ពស់លើការងារមូលដ្ឋាន ពាក់ព័ន្ធទៅនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ ដើម្បីលើកកម្ពស់មុខងារតំណាង មុខងារត្រួតពិនិត្យ និងមុខងារនីតិកម្ម ។ សមាជិក-សមាជិការ ព្រឹទ្ធសភា តាមរយៈយន្តការ (គណៈកម្មការ ក្រុមភូមិភាគ ក្រុមសមាជិកា) បានធ្វើចលនាដោយសកម្ម ដើម្បីស្វែងរកព័ត៌មានអនុវត្តការងារត្រួតពិនិត្យ និងស្វែងយល់អំពីការអនុវត្តច្បាប់នានា ។ ជាពិសេសការរៀបចំវេទិកានៅតាមភូមិភាគ ។ ទន្ទឹមនឹងនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានជម្រុញការបណ្តុះបណ្តាលធនធានមនុស្ស និងបំពេញមុខងាររបស់ខ្លួនយ៉ាងសកម្ម ដើម្បីបម្រើសេវាជូនសមាជិក-សមាជិកា ឲ្យបានល្អប្រសើរ ។/.

ភ្នំពេញ,ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨

**អគ្គលេខាធិការ**

**អ៊ុំ_សារឹទ្ធ**